លេខ ១ - ខែ មករា ឆ្នាំ ១៩៨៨

# រាជកិច្ច

រួមមាន ៖

- ច្បាប់
- ក្រឹត្យ-ច្បាប់
- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ
- សារាចរណែនាំ

Library OM RADSADY

ផ្សាយចេញពីខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីជារៀងរាល់ខែ

Downloaded from http://www.khmerlaws.com

# មាតិកា

ទំព័រ

## I – ក្រុមប្រឹក្សារដ្ឋ

### ក្រឹត្យ

១៣-០១-១៩៨៨ ក្រឹត្យលេខ ០១ ក្រ ស្ដីពីការតែងតាំងសមាសភាពរដ្ឋមន្ត្រី ១

## II – ក្រុមប្រឹក្សារដ្ឋមន្ត្រី

### ១ – អនុក្រឹត្យ

០១-០១-៨៨ អនុក្រឹត្យលេខ ០១ អនក្រ ស្ដីពីការតម្លើងការិយាល័យអគ្គលេខា ធានាលាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ ២

### ២ – សេចក្ដីសម្រេចចិត្ត

០៨-០១-៨៨ សេចក្ដីសម្រេចចិត្តលេខ ០១ សរច ស្ដីពីសម័យប្រជុំសមូហភាពក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី ០១ និង ០២ ខែ មករា ឆ្នាំ ១៩៨៨ ៣

### ៣ – សេចក្ដីសម្រេច

១៤-០១-៨៨ សេចក្ដីសម្រេចលេខ ០២ សសរ ស្ដីពីការកែតម្រូវរយៈពេលរៀនក្នុងប្រការ ២ នៃសេចក្ដីសម្រេចលេខ ១០០ សសរ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ៤

## III – ការងារបណ្ដាក្រសួង

### ១ – ក្រសួងផែនការ

### – សារាចរណែនាំ

១២-០១-៨៨ សារាចរណែនាំលេខ ០១ សរណន-ផកក ស្ដីពីការបោះផ្សាយដីកា ៥

Downloaded from http://www.khmerlaws.com

## ២_ ក្រសួងពាណិជ្ជកម្មក្នុង និង ក្រៅប្រទេស

### សេចក្តីសំរេច

| | | |
|---|---|---|
| ១២-០១-៩៩ | សេចក្តីសំរេចលេខ ០១២ ពណ គបក.សសរ ស្តីពីថ្លៃប្រមូលទិញ សំឡី-គរសុទ្ធ សំឡី-គរមានគ្រាប់ ផ្លែគរស្ងួត និង អប្បហារបន្ថែម លើកទឹកចិត្តឆ្នាំ ១៩៩៨ | ៨ |

## ៣ ក្រសួងត្រួតពិនិត្យ

### សារាចរណែនាំ

| | | |
|---|---|---|
| ១៤-០១-៩៩ | សារាចរណែនាំលេខ ៥១ សរណន ស្តីពីការចាត់តាំង និង សកម្មភាព របស់គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ | ១០ |

Downloaded from http://www.khmerlaws.com

# I- ក្រុមប្រឹក្សារដ្ឋ

## ក្រឹត្យ

## ក្រឹត្យលេខ ០១ ក្រ

### ក្រុមប្រឹក្សារដ្ឋ

### នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- បានឃើញច្បាប់ ស្តីអំពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

**សំរេច**

មាត្រា ១.- ត្រូវបានតែងតាំងជាអនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សមមិត្ត ស៊ិន សេន បច្ចុប្បន្នប្រធាននាយកដ្ឋានស្រាវជ្រាវ និង ស្នងចម្លើយ នៃក្រសួងមហាផ្ទៃ

មាត្រា ២.- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

*ធ្វើនៅភ្នំពេញ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៨៨*

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

**ហេង សំរិន**

Downloaded from http://www.khmerlaws.com

# II– ក្រុមប្រឹក្សារដ្ឋមន្ត្រី

## ១ – អនុក្រឹត្យ

### អនុក្រឹត្យ លេខ ០១ អនក្រ

### ស្តីពីការតម្លើងការិយាល័យអង្គរក្សទៅជានាយកដ្ឋាន ចំណុះ ក្រសួងមហាផ្ទៃ

### ក្រុមប្រឹក្សារដ្ឋមន្ត្រី

– បានឃើញរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

– បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមក្រឹត្យ លេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– ពិនិត្យសំណើ របស់ក្រសួងមហាផ្ទៃ

### សំរេច

មាត្រា១.– តម្លើងការិយាល័យអង្គរក្សដែលបច្ចុប្បន្នចំណុះក្រសួងមហាផ្ទៃផ្ទាល់ អោយទៅជានាយកដ្ឋានអង្គរក្ស ។

មាត្រា២.– ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់នាយកដ្ឋានអង្គរក្សនេះ អាស្រ័យដោយក្រសួងមហាផ្ទៃកំណត់សំរេចដើម្បីអនុវត្ត ។

មាត្រា៣.– នាយកដ្ឋានអង្គរក្សមានប្រធានមួយរូបទទួលខុសត្រូវរួម និង អនុប្រធានមួយចំនួនជំនួយការ ។

មាត្រា៤.– រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីបណ្តាក្រសួង-ស្ថាប័នដែលមានការពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

Downloaded from http://www.khmerlaws.com

មាត្រា ៤ – អនុក្រឹត្យនេះមានអានុភាពគតិយុត្តិ ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

*ភ្នំពេញ,ថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៨៨*

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន-សែន

## ២ – សេចក្តីសំរេចចិត្ត

### សេចក្តីសំរេចចិត្ត លេខ ០១ ស.ស.ច

### ស្តីពីសម័យប្រជុំសម្ពហភាពក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី ០១ និង ០២ ខែ មករា ឆ្នាំ ១៩៨៨

សម័យប្រជុំសម្ពហភាពក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី ០១ និង ០២ ខែ មករា ឆ្នាំ ១៩៨៨ បានឆ្លងពិនិត្យដោយយកចិត្តទុកដាក់លើ :

១ – របាយការណ៍របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីសភាពការណ៍នៃការអនុវត្តការកិច្ចសង្គមកិច្ច រយៈពេល ២ឆ្នាំ ១៩៨៦_១៩៨៧ និងគំរោងទិសដៅផែនការរដ្ឋ ឆ្នាំ ១៩៨៨ ។

២ – របាយការណ៍របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការបូកសរុបសភាពការណ៍ ហិរញ្ញវត្ថុថវិការដ្ឋ ឆ្នាំ ១៩៨៧ ទិសដៅភារកិច្ចហិរញ្ញវត្ថុ និង គំរោងថវិការដ្ឋ ឆ្នាំ ១៩៨៨ ។

– របាយការណ៍របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការបូកសរុបសំរេចទូទាត់ ចំណូលចំណាយថវិការដ្ឋ ឆ្នាំ ១៩៨៦ ។

ក្រោយពីអង្គប្រជុំបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់ និង មានមតិកែសម្រួលនូវចំណុចសំខាន់ ៗ មួយចំនួនក្នុងរបាយការណ៍ទាំងពីរខាងលើរួចមក ក្រុមប្រឹក្សារដ្ឋមន្ត្រីចេញសេចក្តីសំរេចចិត្ត ដូចខាងក្រោមនេះ :

១ – ឯកភាពលើការវាយតម្លៃសភាពការណ៍ នៃការអនុវត្តការកិច្ច សេដ្ឋកិច្ច-សង្គមកិច្ច រយៈពេល ២ឆ្នាំ ១៩៨៦-១៩៨៧ និង គំរោងទិសដៅផែនការរដ្ឋ ឆ្នាំ ១៩៨៨ ។

Downloaded from http://www.khmerlaws.com

២ — ឯកភាពលើការបូកសរុបសភាពការណ៍ ហិរញ្ញវត្ថុ ថវិការដ្ឋ ឆ្នាំ ១៩៨៧ ទិសដៅភារកិច្ចហិរញ្ញវត្ថុ និង គំរោងថវិការដ្ឋ ឆ្នាំ ១៩៨៨ ។

— ឯកភាពលើការបូកសរុបសំរេចទូទាត់ ចំណូល-ចំណាយ ថវិការដ្ឋ ឆ្នាំ ១៩៨៦ ។

៣ — ឯកភាពប្រគល់ភារកិច្ច អោយរដ្ឋមន្ត្រីក្រសួងផែនការ និងរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ធ្វើការបែងចែកកំរិតកំណត់ផែនការ ស្ដីពីភារកិច្ច-សង្គមកិច្ច និង ថវិការដ្ឋ ប្រចាំឆ្នាំជាបន្ទាន់ ជូនបណ្ដាក្រសួង ស្ថាប័ន និង ខេត្ត - ក្រុង ដើម្បីអនុវត្តមុខសភាអនុម័ត ។

បណ្ដាក្រសួង និង អគ្គនាយកដ្ឋាន ចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវត្រៀមលក្ខណៈសម្បត្តិ ដើម្បីធានាអនុវត្តសេចក្ដីសំរេចចិត្តនេះ តាមភារកិច្ចរៀងៗខ្លួន អោយបានឆាប់រហ័សនិងមានប្រសិទ្ធភាព ។

ភ្នំពេញ, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៨៨

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន សែន

## ៣ សេចក្ដីសំរេច

## សេចក្ដីសំរេច លេខ ០២ ស.ស.រ

## ស្ដីពីការកែតម្រូវរយៈពេលរៀន ក្នុងប្រការ ២ នៃ សេចក្ដីសំរេចលេខ ១៦៦ ស.ស.រ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

— បានឃើញច្បាប់ ស្ដីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ.ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

Downloaded from http://www.khmerlaws.com

– បានឃើញសេចក្ដីសំរេចលេខ ១៦៦ សសរ. ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៨៧ ស្ដីពីអាហារូបករណ៍សិស្ស និស្សិត និង កម្មាភិបាល បុគ្គលិក កម្មករ រដ្ឋដែលទៅបន្តការសិក្សា របបឧបត្ថម្ភជីវភាពអន្តេវាសិក និង ប្រាក់កម្រៃម៉ោងបន្ថែម ។

– តាមការចាំបាច់ចំពោះមុខ

## សំរេច

**ប្រការតែមួយ** : ចំពោះរយៈពេលរៀនក្នុងប្រការ ២ ចំណុចនៅរដ្ឋធានីភ្នំពេញ និងភូមិភាគព្លសាន ស្ដីពីការកំណត់របបឧបត្ថម្ភជីវភាពអន្តេវាសិកដ្ឋានប្រចាំថ្ងៃដល់សិក្ខាកាមគ្រប់ប្រភេទ ត្រូវបានអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចអោយមកសិក្សា ឬ ធ្វើក្រឹតការសុក្រឹត្យការ ឬ បំប៉នមុខជំនាញផ្សេងៗ ត្រូវបានកែសម្រួលដូចខាងក្រោមនេះ :

| | ទីកន្លែង | រយៈពេលរៀន | ប្រាក់ឧបត្ថម្ភជីវភាពប្រចាំថ្ងៃ អន្តេវាសិក | របបអង្ករតាមថ្ងៃធានាអាជីវកម្ម |
|---|---|---|---|---|
| ពីសេចក្ដីថា : | រដ្ឋធានីភ្នំពេញ និងភូមិភាគព្លសាន | តិចជាង ១៦ ខែ | ២៥រ៍00 | ១៦ គ.ក្រ |
| មកជា : | រដ្ឋធានីភ្នំពេញ និងភូមិភាគព្លសាន | តិចជាង ១២ ខែ | ២៥រ៍00 | ១៦ គ.ក្រ |

ក្រៅពីនេះគឺរក្សាទុកនៅដដែលពុំមានការកែប្រែទេ ។

ភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៨៨

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធានស្ដីទី

ហត្ថលេខា និង ត្រា

ចា សុទ

Downloaded from http://www.khmerlaws.com

# III- ការងារបណ្ដាក្រសួង

## ១- ក្រសួងផែនការ

### *សារាចរណែនាំ*

### សារាចរណែនាំ លេខ ០១ សរណន-ផក.គ

ស្ដីពីការដោះដូរ ជីគីមី

### រដ្ឋមន្ត្រីក្រសួងផែនការ

*ជំរាបជូន*

— សមមិត្តរដ្ឋមន្ត្រីក្រសួងកសិកម្ម
— សមមិត្តរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
— សមមិត្តរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ
— សមមិត្តប្រធានធនាគារជាតិនៃប្រជាជនកម្ពុជា
— សមមិត្តប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត - ក្រុង

យោងសេចក្ដីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ៧៥៤ សសរ. ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៨៧ .

យោងលិខិតរបស់ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ១៥៨០ សជណ - កស ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៨៧ .

យោងសារាចរណែនាំរបស់ក្រសួងពាណិជ្ជកម្មលេខ ១២ ពណ - គបក - សរណន ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៨៧ .

យោងលិខិតរបស់ក្រសួងកសិកម្មលេខ ៧០៨៣ កសក-គហ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៨៧

ក្រោយពីបានឯកភាពជាមួយក្រសួងហិរញ្ញវត្ថុ ក្រសួងផែនការសូមធ្វើការណែនាំ ការដោះដូរជីគីមីគ្រប់ប្រភេទជាមួយស្រូវក្នុងឆ្នាំ ១៩៨៨ ដូចខាងក្រោម ៖

Downloaded from http://www.khmerlaws.com

១ - ការដោះដូរជីគីមីជាមួយស្រូវក្នុងឆ្នាំ ១៩៨៨ តាមអត្រាដូចតារាងខាងក្រោម ៖

| *ល-រ* | *ប្រភេទជី* | *ស្រូវហូប គ.ក្រ* |
|---|---|---|
| ១ — | អាម៉ូហ្វុស | ៣, ០០ |
| ២ — | អ៊ុយរ៉េ ៤៦ភាគរយ អ៊ិន | ២, ០០ |
| ៣ — | ១៦ . ២០ . ០ | ២, ៥០ |
| ៤ | ស៊ុលហ្វាតអាម៉ូនិញ៉ូម ២៣ភាគរយ អ៊ិន | ១, ០០ |
| ៥ — | ស៊ុបពែហ្វូសហ្វាត | ១, ០០ |
| ៦ — | ក្លរៀជីប៉ូតាស្យូម | ១, ០០ |
| ៧ — | ១៥ . ១៥ . ១៥ | ២, ០០ |
| ៨ — | ស៊ុលហ្វាតជីប៉ូតាស្យូម | ១, ០០ |
| ៩ — | ១៦ . ២០ . ៣ | ២, ៥០ |
| ១០ — | ១៦ . ២០ | ១, ០០ |
| ១១ — | ១៨ . ៤៦ . ០ | ៣, ០០ |

២ — ចំពោះជីហ្វូសហ្វាតផលិតក្នុងប្រទេស ក្រុមប្រឹក្សារដ្ឋមន្ត្រី បានប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម និង ក្រសួងឧស្សាហកម្ម ពិភាក្សាគ្នាដើម្បីកំណត់ថ្លៃជីហ្វូសហ្វាតផលិតក្នុងប្រទេសជាសាច់ប្រាក់លក់ជូនប្រជាជន ដោយត្រូវធានាថ្លៃដើមរបស់រោងចក្រ មានចំណេញដល់អង្គភាពផលិតកម្ម ធានាចំណាយចរាចរ និង ពុំគិតចំណូលរដ្ឋឡើយ ។

៣ — ក្រសួងកសិកម្ម មានភារកិច្ចដឹកជញ្ជូនជីពីឃ្លាំងមជ្ឈិមរហូតដល់ឃ្លាំងស្រុក ហើយបានទទួលអប្បហារ ៩ ភាគរយនៃថ្លៃជី គិតជាស្រូវ ។

៤ — ការបញ្ចុះជីពីមូលដ្ឋានស្រុក ខ័ណ្ឌ ទៅ ឃុំ ឬ សង្កាត់ អនុញ្ញាតអោយប្រើប្រាស់បន្ថែមអប្បហារ ១ភាគរយ « ១% » ដោយត្រូវគិតលើថ្លៃជីដូរស្រូវ ។

៥ — *ការដោះដូរជីជាមួយស្រូវ ៖* ការដោះដូរជីជាមួយស្រូវ ហើយប្រមូលស្រូវយកមកប្រគល់ជូនពាណិជ្ជកម្មរដ្ឋនៅត្រង់ចំណុចដូចគ្នា នឹង ចំណុចដែលចិស្នាក់ការ ដេប៉ូទិញ-លក់ ឬ អាគារសហករណ៍ ប្រគល់ជូនពាណិជ្ជកម្មរដ្ឋ ត្រូវបានអប្បហារបន្ថែមចំនួន ២២០ ៛ ក្នុងស្រូវ ១ តោន ។

Downloaded from http://www.khmerlaws.com

៦ – មូលដ្ឋានណាដែលពុំទាន់មានស្រូវផ្គូរផ្គងលំដៃ ត្រូវធ្វើកិច្ចសន្យាបណ្តាក់ជីដោយត្រូវសងវិញជាស្រូវនៅពេលប្រមូលផល ។

សារាចរណែនាំនេះ ត្រូវប្រកាសផ្សាយទូលាយអោយប្រជាជនបានជ្រួតជ្រាប ។ អង្គភាពមានភារកិច្ចដោះដូរជីគីមីជាមួយប្រជាជន ត្រូវអនុវត្តអោយបានត្រឹមត្រូវតាមខ្លឹមសារខាងលើ ។

ភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៨៨
រដ្ឋមន្ត្រីក្រសួងផែនការ
ហត្ថលេខា និង ត្រា
ជា ចាន់តូ

✳✳✳✳✳✳✳✳

## ២– ក្រសួងពាណិជ្ជកម្មក្នុង និង ក្រៅប្រទេស

## សេចក្តីសំរេច

### សេចក្តីសំរេច លេខ ០១២ ពណ.គបត.សស

### ស្តីពី ថ្លៃប្រមូលទិញសំឡីគរស្ទុទ្ធ សំឡីគរមានគ្រាប់ ផ្លែគរស្ងួត និងអច្បហារបន្ថែម រង្វាន់ លើកទឹកចិត្ត ឆ្នាំ ១៩៨៨

### រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

– យោងសេចក្តីសំរេចលេខ ៩៩-៨០ គប ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៨០

– របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ស្តីពីភារកិច្ច សិទ្ធិអំណាច អង្គការចាត់តាំងក្រសួងពាណិជ្ជកម្ម

– យោងសេចក្តីសំរេចលេខ ១១១ សសរ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

– យោងសេចក្តីសំរេចលេខ ១២១ សសរ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

– ក្រោយបានការឯកភាព ពីក្រសួងផែនការ

Downloaded from http://www.khmerlaws.com

# សំរេច

ប្រការ ១ ៖ ថ្លៃប្រមូលទិញ សំឡីគរសុទ្ធ, សំឡីគរលាយគ្រប់, និងផ្លែគរស្ងួត ពីប្រជាជន ឆ្នាំ ១៩៨៨ មានដូចខាងក្រោមនេះ

| ល.រ | រាយតាមប្រភេទ | ឯកតាគិត | ថ្លៃប្រមូលទិញ |
|---|---|---|---|
| ១ | សំឡីគរសុទ្ធគ្មានគ្រាប់, គ្មានបណ្ដូល | គ.ក្រ | ៣០រ៉ៀល០០ |
| ២ | សំឡីគរមានគ្រាប់ គ្មានបណ្ដូល | – | ១២រ៉ៀល១០ |
| ៣ | ផ្លែគរស្ងួត | – | ៦រ៉ៀល០០ |

ប្រការ ២ ៖ អបហារបន្ថែម រង្វាន់លើកទឹកចិត្ត និង ថ្លៃប្រគល់ទទួលរវាងខេត្ត និងមជ្ឈមត្រូវបានកំណត់ដូចតទៅ ៖

| ល.រ | រាយតាមប្រភេទ | ឯកតាគិត | អបហារបន្ថែម | រង្វាន់លើកទឹកចិត្ត | ថ្លៃប្រគល់ទទួល |
|---|---|---|---|---|---|
| ១ | សំឡីគរសុទ្ធគ្មានគ្រាប់គ្មានបណ្ដូល | គ.ក្រ | ២រ៉ៀល៤០ | ២រ៉ៀល១០ | ៣៤រ៉ៀល៥០ |
| ២ | សំឡីគរមានគ្រាប់ គ្មានបណ្ដូល | - | ០រ៉ៀល៩៦ | ០រ៉ៀល៨៤ | ១៣រ៉ៀល៨០ |
| ៣ | ផ្លែគរស្ងួត | – | ០រ៉ៀល៤៨ | ០រ៉ៀល៤២ | ៦រ៉ៀល៩០ |

— ចំពោះអបហារបន្ថែម ក្រសួងប្រគល់ភារកិច្ចជូនគណៈកម្មាធិការប្រជាជនបដិវត្តន៍ខេត្តធ្វើការកំណត់បែងចែកជាក់ស្ដែង ទៅតាមសភាពការណ៍ជាក់ស្ដែងក្នុងមូលដ្ឋានរបស់ខ្លួន ។

ប្រការ ៣៖ ចំពោះគុណភាពត្រូវបានកំណត់ដូចតទៅ ៖

— សំឡីគរសុទ្ធគ្មានគ្រាប់-គ្មានបណ្ដូល ៖ ស្ងួតល្អ-ពណ៌ស គ្មានវត្ថុធាតុលាយចំរុះ ។

— សំឡីគរមានគ្រាប់-គ្មានបណ្ដូល ៖ សំឡីស្ងួត ពណ៌ស គ្មានកំទេចកំទីលាយ ។

— ផ្លែគរស្ងួត ៖ ទុំល្អ ហាលស្ងួត គ្មានស្អុយ ។

ប្រការ ៤ ៖ សមមិត្តប្រធានក្រុមហ៊ុនកម្ពុជា និហារ៍ណ - អាហារ៍ណ សមមិត្តប្រធានមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង សមមិត្តប្រធានមន្ទីរ និង នាយកដ្ឋានរបស់ក្រសួងមានភារកិច្ចអនុវត្តន៍តាមសេចក្ដីសំរេចនេះ ។

Downloaded from http://www.khmerlaws.com

សេចក្តីសំរេចនេះមានប្រសិទ្ធភាពអនុវត្តន៍ ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៨៨

ភ្នំពេញ, ថ្ងៃទី ១៦ ខែ ០១ ឆ្នាំ ១៩៨៨
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ហត្ថលេខា និង ត្រា
ហូ ណាន

## ៣- ក្រសួងត្រួតពិនិត្យ

## សារាចរណែនាំ

## សារាចរណែនាំ លេខ ៩១ សរណន

### ស្តីពីការចាត់តាំង និង សកម្មភាពរបស់គណៈកម្មាធិការ ត្រួតពិនិត្យ គ្រប់ថ្នាក់

បដិវត្តកម្ពុជាកំពុងស្ថិតក្នុងប្រៀបខ្សាំង ប្រៀបឈ្នះនិង ឈានទៅរកការរីកចំរើនឥតឈប់ឈរ កន្លងមក ស្ថាប័នត្រួតពិនិត្យបានបង្កើតឡើងនៅមជ្ឈិម និង មាននៅត្រឹមក្រសួងខេត្ត-ក្រុង ឯចំនួនក្របខ័ណ្ឌកម្មាភិបាលធ្វើការត្រួតពិនិត្យ ក៏មានកំរិតសមស្របនឹងសភាពការណ៍ជាក់ស្តែងនាពេលនោះ ។ ប៉ុន្តែនៅពេលបច្ចុប្បន្ន និង ទៅអនាគត ស្ថាប័នត្រួតពិនិត្យត្រូវបានពង្រឹង និង ពង្រីកបន្ថែមទាំងបរិមាណនិងគុណភាព ដើម្បីរួមចំណែកជួយដល់អ្នកដឹកនាំនៃស្ថាប័នគ្រប់ថ្នាក់ លើកកំពស់ស្មារតីទទួលខុសត្រូវ បង្កើនបាននូវប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយរបស់បក្ស ច្បាប់ និងផែនការរដ្ឋ ។ ផ្តើមចេញពីនេះក្រុមប្រឹក្សារដ្ឋមន្ត្រីបានប្រកាសប្រើ និងដាក់អោយអនុវត្តអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៨៧ ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ។

ផ្អែកតាមសេចក្តីណែនាំ លេខ ២២២ ចតមឈ ចុះថ្ងៃទី ១៨.០៥.៨៣ របស់គណៈចាត់តាំងមជ្ឈិម ស្តីពីការពង្រឹងក្បាលម៉ាស៊ីនចាត់តាំង នឹងក្របខ័ណ្ឌរបស់បណ្តាមន្ទីរ ក្រសួង និង មូលដ្ឋាន និង ដើម្បីដំណើរការចាត់តាំងធ្វើសកម្មភាពបានត្រឹមត្រូវ ក្រសួងត្រួតពិនិត្យសូមធ្វើការណែនាំចំណុចសំខាន់មួយចំនួនស្តីពីទីតាំង តួនាទីភារកិច្ច សិទ្ធិអំណាច អង្គការចាត់តាំង របៀបរបប

Downloaded from http://www.khmerlaws.com

ធ្វើការ និង ទំនាក់ទំនងការងាររបស់គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ដូចតទៅ ៖

*I — ទីតាំង តួនាទី ភារកិច្ច និងសិទ្ធិអំណាច*

*១ — ទីតាំងតួនាទី*

គណៈកម្មាធិការត្រួតពិនិត្យថ្នាក់ណា គឺជាផ្នែកជំនួយការអោយរដ្ឋអំណាចថ្នាក់នោះមានមុខងារត្រួតពិនិត្យជាប្រចាំ ទាន់ពេលវេលា និង ប្រាកដប្រជា នូវរាល់ការអនុវត្តគោលការណ៍ គោលនយោបាយ សេចក្តីសំរេច សារាចរ ផែនការរដ្ឋសំដៅលើកកំពស់ស្មារតីទទួលខុសត្រូវ រួមចំណែកកែលំអរការចាត់តាំង និង របៀបរបបធ្វើការ ព្រមទាំងជាជំនួយដល់អង្គការដឹកនាំធ្វើការត្រួតពិនិត្យ អោយបានត្រឹមត្រូវឡើងវិញ នូវគោលការណ៍ គោលនយោបាយសេចក្តីសំរេច សារាចរ ផែនការទាំងនោះ ។ សកម្មភាពត្រួតពិនិត្យ គឺសំដៅពង្រីកនូវគុណសម្បត្តិ ដើម្បីសំណូមពរស្ថាប័នសាមីលើកសរសើរ និង រារាំង កែលំអ ឬ វិនិច្ឆ័យនូវគុណវិបត្តិ អោយបានទាន់ពេលវេលា។

— គណៈកម្មាធិការត្រួតពិនិត្យទីស្តីការរដ្ឋមន្ត្រី និង ស្ថាប័នថ្នាក់ប្រហាក់ប្រហែលនៅខ្សែម គឺជាសេនាធិការជួយដល់ថ្នាក់ដឹកនាំនៅស្ថាប័ននោះ ក្នុងការចាត់តាំង និង ធ្វើសកម្មភាពត្រួតពិនិត្យរាល់កិច្ចការរបស់ទីស្តីការរដ្ឋមន្ត្រី ឬ ស្ថាប័នថ្នាក់ប្រហាក់ប្រហែលនោះ និង ទទួលការណែនាំមុខជំនាញត្រួតពិនិត្យពីក្រសួងត្រួតពិនិត្យ ។

— គណៈកម្មាធិការត្រួតពិនិត្យខេត្ត-ក្រុង គឺជាសេនាធិកាជួយដល់គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត ក្រុង ក្នុងការចាត់តាំង និង ធ្វើសកម្មភាពត្រួតពិនិត្យ រាល់កិច្ចការរបស់ខេត្ត - ក្រុងនោះ និងទទួលការណែនាំមុខជំនាញត្រួតពិនិត្យពីក្រសួងត្រួតពិនិត្យ ។

— គណៈកម្មាធិការត្រួតពិនិត្យស្រុក ទីរួមខេត្ត ខ័ណ្ឌ ស្រុកជាយក្រុង គឺជាសេនាធិការជួយដល់គណៈកម្មាធិការប្រជាជនបដិវត្តស្រុក ទីរួមខេត្ត ខ័ណ្ឌ ស្រុកជាយក្រុង ក្នុងការចាត់តាំង និង ធ្វើសកម្មភាពត្រួតពិនិត្យរាល់កិច្ចការរបស់ស្រុក ទីរួមខេត្ត ខ័ណ្ឌ ស្រុកជាយក្រុងនោះ និងទទួលការណែនាំមុខជំនាញត្រួតពិនិត្យ ពីស្ថាប័នត្រួតពិនិត្យថ្នាក់លើ ។

*២ — ភារកិច្ច*

គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ មានភារកិច្ចដូចខាងក្រោម ៖

ក — ត្រួតពិនិត្យការគោរពប្រតិបត្តិនូវរាល់គោលនយោបាយ គោលការណ៍ ក៏ដូចជាត្រួតពិនិត្យរាល់ការគោរពប្រតិបត្តិច្បាប់ ក្រឹត្យ - ច្បាប់ អនុក្រឹត្យ សេចក្តីសំរេច សារាចរ សារាចរណែនាំរបស់ថ្នាក់លើ ដែលដាក់ចុះអោយក្រសួង ខេត្ត-ក្រុងអនុវត្ត និងរាល់ទំនាក់ទំនងរបបកំណត់

Downloaded from http://www.khmerlaws.com

ឬ បទបញ្ញត្តិដែលក្រសួងខេត្ត និងថ្នាក់របស់ខ្លួនបានលើកឡើង ។ ទន្ទឹមនឹងនេះ ក៏មានភារកិច្ចត្រួតពិនិត្យការអនុវត្តផែនការរបស់ថ្នាក់លើ និងផែនការរបស់ថ្នាក់ខ្លួន ដោយផ្អែកតាមសភាពការណ៍ជាក់ស្តែង ស្រាវជ្រាវរកស្រង់នូវបញ្ហាសំខាន់ៗជាគន្លឹះ តាមសំណូមពរដឹកនាំរបស់ថ្នាក់លើ និងថ្នាក់ដឹកនាំរបស់ខ្លួន ក៏ដូចជាផែនការណែនាំរបស់ស្ថាប័នត្រួតពិនិត្យថ្នាក់លើ ដើម្បីស្នើឡើង និងចាត់តាំងការត្រួតពិនិត្យអោយបានម៉ឺងម៉ាត់ សំដៅរួមចំណែកជំរុញអោយការអនុវត្តផែនការរដ្ឋបានសំរេចលទ្ធផលល្អ ។

ខ – ចាត់តាំងទទួលប្រជាជនដែលមកប្តឹងតវ៉ា ឬ ប្តឹងបរិហារអោយបានត្រឹមត្រូវនិងទទួលពិនិត្យដោះស្រាយបណ្តឹងតវ៉ា បណ្តឹងបរិហាររបស់ពលរដ្ឋដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួនព្រមទាំងចាត់បញ្ជូនពាក្យបណ្តឹងដែលមិនស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ទៅអោយស្ថាប័នដែលមានសមត្ថកិច្ចពិនិត្យដោះស្រាយ អោយទាន់តាមថេរវេលាកំណត់ក្នុងច្បាប់ ស្តីពីការពិនិត្យដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២០ សីហា ១៩៨២ ។ ទន្ទឹមនេះក៏មានភារកិច្ចតាមដាន ក្រើនរំលឹក និង ត្រួតពិនិត្យជាប្រចាំ នូវរាល់ដំណោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងបរិហារ ដែលស្ថាប័នមានសមត្ថកិច្ចទទួលយកទៅដោះស្រាយ ដើម្បីរួមចំណែកក្នុងការពង្រឹងនីត្យានុកូលភាពសង្គមនិយម ធានានូវសិទ្ធិប្តឹងតវ៉ា និង ប្តឹងបរិហាររបស់ពលរដ្ឋ ។

គ – នៅពេលដែលមានលទ្ធភាពចាត់តាំងបានគណៈកម្មាធិការ ត្រួតពិនិត្យថ្នាក់ក្រោមរបស់ខ្លួនគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ នៅថែមទាំងមានភារកិច្ចណែនាំមុខជំនាញត្រួតពិនិត្យ ក៏ដូចជាមុខជំនាញទទួលពិនិត្យដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងបរិហាររបស់ពលរដ្ឋ ដល់គណៈកម្មាធិការត្រួតពិនិត្យថ្នាក់ក្រោម និង គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជនតាមមូលដ្ឋានសំដៅជួយអោយការចាត់តាំង និងធ្វើសកម្មភាពនៃគណៈកម្មាធិការត្រួតពិនិត្យទាំងនោះ បានត្រឹមត្រូវតាមតួនាទី ភារកិច្ច និង សិទ្ធិអំណាចរបស់ខ្លួន ។

៣ – *សិទ្ធិ អំណាច*

ដើម្បីធានាដល់ការអនុវត្តភារកិច្ចខាងលើបានល្អ គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់មានសិទ្ធិដូចតទៅ :

ក – យោងតាមភារកិច្ចចំពោះមុខ និង សំណូមពរចាំបាច់នៃការងារដឹកនាំរបស់មូលដ្ឋាន ក៏ដូចជាផ្អែកតាមផែនការណែនាំនៃស្ថាប័នត្រួតពិនិត្យថ្នាក់លើ គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ មានលើកឡើងនូវកម្មវិធីជាក់ស្តែង ស្នើរដ្ឋមន្ត្រី ឬ ប្រធានគណៈកម្មាធិការប្រជាជនបដិវត្ត

Downloaded from http://www.khmerlaws.com

ដើម្បីសុំសេចក្តីសំរេចចាត់តាំងការត្រួតពិនិត្យ ចាត់តាំងគណៈប្រតិភូ ឬ កម្មាភិបាលអោយចុះត្រួតពិនិត្យតាមខ្លឹមសារនៅមុខសញ្ញាដែលបានឯកភាពទាំងនោះ ។

ខ — មានសិទ្ធិកោះអញ្ជើញប្រធានបណ្តាស្ថាប័ន អង្គភាព ឬ កម្មាភិបាល ដើម្បីប្រជុំពិភាក្សារាល់បញ្ហាដែលពាក់ព័ន្ធដល់ការត្រួតពិនិត្យ ឬ ការងារទទួលពិនិត្យដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងបរិហាររបស់ពលរដ្ឋ ព្រមទាំងមានសិទ្ធិចាត់តាំងកម្មាភិបាលអោយចូលរួមប្រជុំការងារដែលមានទំនាក់ទំនងដល់ការងារត្រួតពិនិត្យ តាមសំណើរបស់អង្គភាពនានានៅមូលដ្ឋានរបស់ខ្លួន។

គ — មានសិទ្ធិសំណូមពរអោយបុគ្គលឬអង្គភាពដែលត្រូវត្រួតពិនិត្យ ឬពាក់ព័ន្ធនឹងការងារត្រួតពិនិត្យ អោយផ្តល់នូវឯកសារ បំភ្លឺរាល់ឧប្បត្តិហេតុ ពត៌មាន សភាពការណ៍ ឬ សន្និដ្ឋានបញ្ជាក់រាល់បញ្ហាដែលស្ថិតក្នុងក្រចខ័ណ្ឌនៃការទទួលខុសត្រូវរបស់ខ្លួន ក៏ដូចជាផ្តល់កម្មាភិបាលអោយចូលរួមសហការៈតាមសំណូមពរការងារត្រួតពិនិត្យ ។ ជាមួយនេះដែរ ត្រូវជួយបង្កលក្ខណៈងាយស្រួលអោយគណៈប្រតិភូ ឬ កម្មាភិបាលត្រួតពិនិត្យ បានជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាជន មហាជន ដើម្បីធានាអោយការងារត្រួតពិនិត្យមានប្រសិទ្ធភាព និង សត្យានុម័ត ។

ឃ — ដើម្បីធានាដល់កិច្ចការពារផលប្រយោជន៍រដ្ឋ សមូហភាព និង ផលប្រយោជន៍ស្របច្បាប់របស់ពលរដ្ឋ ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ មានសិទ្ធិផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តទាំងឡាយណា ដែលពិនិត្យឃើញថា កំពុងតែ ឬ រៀបនឹង បង្កឡើងនូវមហន្តរាយធ្ងន់ធ្ងរដល់នយោបាយសេដ្ឋកិច្ច ឬ ជីវភាពរស់នៅរបស់ប្រជាជន ដែលស្ថិតក្នុងមូលដ្ឋាន និងសមត្ថកិច្ចរបស់ខ្លួន រួចរាយការណ៍ជាបន្ទាន់ជូនថ្នាក់លើរបស់ខ្លួន ។ ជាមួយនេះដែរ ក្នុងករណីចាំបាច់និងជាបន្ទាន់ក៏មានសិទ្ធិផ្អាកជាបណ្តោះអាសន្ននូវសកម្មភាពរបស់បុគ្គល ឬ អង្គភាពដែលត្រូវត្រួតពិនិត្យមានឋានៈក្រោមមួយថ្នាក់ដែលបង្កការរាំងស្ទះដល់ការងារត្រួតពិនិត្យ និង ផ្អាកជាបណ្តោះអាសន្ននូវសេចក្តីសំរេចរបស់អង្គភាពត្រូវត្រួតពិនិត្យ ក្នុងការចាត់តាំង ឬ ផ្ទេរកម្មាភិបាលបុគ្គលិក ដែលពាក់ព័ន្ធដល់ការងារត្រួតពិនិត្យ ទៅកន្លែងផ្សេង អង្គភាពផ្សេង ឬ ក៏ផ្លាស់ចេញនូវកម្មាភិបាលដែល កំពុងរួមសហការត្រួតពិនិត្យរួចរាយការណ៍ជូនថ្នាក់លើរបស់ខ្លួន ។

នៅពេលដែលបុគ្គល ឬ អង្គភាពដែលត្រូវត្រួតពិនិត្យ មិនព្រមអនុវត្តតាមការផ្អាកនេះ ប្រធានគណៈកម្មាធិការត្រួតពិនិត្យ ត្រូវរាយការណ៍ជូនថ្នាក់ដឹកនាំដែលគ្រប់គ្រងបុគ្គល ឬ អង្គភាពនោះ និងថ្នាក់លើរបស់ខ្លួន ដើម្បីមានវិធានការដោះស្រាយ ។

ដើម្បីចៀសវាងការរាំងស្ទះ ឬ ប៉ះពាល់ដល់អាជីវកម្ម ផលិតកម្ម និង ការគ្រប់គ្រង ការផ្អាក

Downloaded from http://www.khmerlaws.com

បណ្តឹងឧទ្ធរណ៍នេះ ត្រូវធ្វើដោយប្រុងប្រយ័ត្នបំផុត ពោលគឺរាល់ការផ្អាកត្រូវធ្វើឡើងក្នុងស្មារតីទទួលខុសត្រូវខ្ពស់បំផុត សក្សានុម័ត គ្រប់ជ្រុងជ្រោយ ប្រាកដប្រជា និង ទាន់ពេលវេលា ហើយស្ថិតក្នុងករណីដែលចាំបាច់បំផុត ។ មានតែសមមិត្តប្រធានគណៈកម្មាធិការត្រួតពិនិត្យទេទើបមានសិទ្ធិផ្អាក ដោយឡែកកម្មាភិបាល ឬ គណៈប្រតិភូត្រួតពិនិត្យពុំមានសិទ្ធិផ្អាកឡើយ ប៉ុន្តែបើពិនិត្យឃើញករណីដែលត្រូវផ្អាកនោះ ត្រូវរាយការណ៍ជូន សមមិត្ត ប្រធានគណៈកម្មាធិការត្រួតពិនិត្យដើម្បីពិនិត្យសំរេច ។

៦ — នៅក្រោយការត្រួតពិនិត្យ និង ការពិនិត្យដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហារ មួយលើក ។ គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ មានសិទ្ធិសន្និដ្ឋាន វាយតម្លៃបញ្ជាក់មូលហេតុលើកឡើងអោយច្បាស់ពីទង្វើត្រូវ និង ខុសរបស់បុគ្គល ឬ អង្គភាពដែលបានត្រួតពិនិត្យរួចធ្វើសំណូមពរឡើងថ្នាក់ដឹកនាំដើម្បីពិនិត្យសំរេច សរសើរជូនរង្វាន់ កែលំអ ដាក់វិន័យរដ្ឋបាល ឬ បញ្ជូនទៅតុលាការវិនិច្ឆ័យតាមច្បាប់ ។ ពេលទទួលបាននូវសេចក្តីសំរេចពីថ្នាក់ដឹកនាំហើយ គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ នៅមានសិទ្ធិតាមដានការអនុវត្តសេចក្តីសំរេចនោះ ថែមទាំងមានសិទ្ធិត្រួតពិនិត្យស្ថាប័នដែលមិនព្រមអនុវត្តនូវសេចក្តីសំរេចនោះទៀតផង ។

គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ពុំអនុញ្ញាតដោយផ្អែកលើសិទ្ធិអំណាចនេះចូលជ្រៀតជ្រែកក្នុងសកម្មភាពជំនុំជំរះរបស់តុលាការ និង អយ្យការឡើយ ។

ចំពោះតួនាទីភារកិច្ច សិទ្ធិអំណាចខាងលើ ត្រូវបានកំណត់សំរាប់គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ដែលក្នុងនោះរួមទាំងគណៈកម្មាធិការត្រួតពិនិត្យក្រសួងការពារប្រទេស ក្រសួងមហាផ្ទៃ និង ធនាគារជាតិនៃប្រជាជនកម្ពុជាផងដែរ ។ ដោយឡែក គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ក្រៅពីគណៈកម្មាធិការត្រួតពិនិត្យទាំងបី គ្មានសិទ្ធិត្រួតពិនិត្យអង្គភាព យោធា នគរបាល និងឃ្លាំងធនាគារឡើយ ។ បើក្នុងករណីត្រូវត្រួតពិនិត្យអង្គភាពទាំងនេះ គឺអាស្រ័យដោយគណៈកម្មាធិការប្រជាជនបដិវត្តចេញសេចក្តីសំរេច ក្រោយពីបានការឯកភាពពីស្ថាប័នថ្នាក់លើរបស់អង្គភាពនោះ ។

*II — អង្គការចាត់តាំងគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់*

ការចាត់តាំងបង្កើតគណៈកម្មាធិការត្រួតពិនិត្យ គឺជាភារកិច្ចចាំបាច់ និង បន្ទាន់របស់ថ្នាក់ដឹកនាំនៅគ្រប់ថ្នាក់ពីមជ្ឈិមរហូតដល់មូលដ្ឋាន ប៉ុន្តែផ្អែកតាមស្ថានភាពការណ៍ជាក់ស្តែងរបស់មូលដ្ឋាន ការចាត់តាំងបង្កើតនេះ ក៏ត្រូវតែដំណើរការក្នុងស្មារតីទទួលខុសត្រូវ និង ប្រុងប្រយ័ត្នបដិវត្តខ្ពស់ ធានាអោយបានល្អប្រសើរទាំងបរិមាណ ទាំងគុណភាព ។

Downloaded from http://www.khmerlaws.com

ដើម្បីមានមូលដ្ឋានជួយដល់ការចាត់តាំងគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ក្រសួងសូមណែនាំបញ្ហាមួយចំនួនដូចតទៅ ៖

*– ការចាត់តាំងគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់*

ប្រព័ន្ធចាត់តាំងស្ថាប័នត្រួតពិនិត្យថ្នាក់ក្រោមក្រសួងត្រួតពិនិត្យ គឺ គណៈកម្មាធិការត្រួតពិនិត្យដែលស្ថិតនៅតាមទីស្ដីការរដ្ឋមន្ត្រី និង ស្ថាប័នថ្នាក់ប្រហាក់ប្រហែលនាយដ្ឋាន នៅតាមខេត្ត ក្រុង ស្រុក ទីរួមខេត្ត ខណ្ឌ ស្រុកជាប់ក្រុង ទូទាំងប្រទេស ។

*ក ចំពោះទីស្ដីការរដ្ឋមន្ត្រី និង ស្ថាប័នថ្នាក់ប្រហាក់ប្រហែលនាយដ្ឋាន*

ការរៀបចំចាត់គណៈកម្មាធិការត្រួតពិនិត្យរបស់ទីស្ដីការរដ្ឋមន្ត្រី និង ស្ថាប័នថ្នាក់ប្រហាក់ប្រហែលនាយដ្ឋាន សំដៅលើស្ថាប័នទាំងឡាយណាដែលមានទំហំការងារធំ គ្រប់គ្រងធំទូលាយនូវទ្រព្យសម្ភារៈ បរិក្ខារ ហិរញ្ញវត្ថុ មានប្រព័ន្ធផលិតកម្ម អាជីវកម្មសំខាន់ៗ ច្រើនដែលផ្សារភ្ជាប់នឹងខឿនសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ជាតិ ជាពិសេសមានទំនាក់ទំនងនឹងជីវភាពរស់នៅរបស់ប្រជាជន ។

ទីស្ដីការរដ្ឋមន្ត្រី ស្ថាប័នថ្នាក់ប្រហាក់ប្រហែលនាយដ្ឋាន ដែលចាំបាច់ត្រូវបង្កើតគណៈកម្មាធិការត្រួតពិនិត្យ រួមមានទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, ឧស្សាហកម្ម, គមនាគមន៍ និង ប្រៃសណីយ៍, កសិកម្ម, ហិរញ្ញវត្ថុ, អប់រំ, សុខាភិបាល, ការបរទេស, មហាផ្ទៃ, យុទ្ធជនពិការ និង សង្គមកិច្ច, ឃោសនាការនិងវប្បធម៌, អគ្គនាយកដ្ឋានចំការកៅស៊ូ, អគ្គនាយកដ្ឋានសំណង់ ធនាគារជាតិនៃប្រជាជនកម្ពុជា ។

គណៈកម្មាធិការត្រួតពិនិត្យ ក្រសួង ឬអគ្គនាយកដ្ឋាននាយដ្ឋាន មានថ្នាក់ស្មើនាយកដ្ឋាន ដែលមានប្រធាន ០១រូប និង អនុប្រធានជំនួយការ ។ គណៈកម្មាធិការត្រួតពិនិត្យក្រសួង ឬ អគ្គនាយកដ្ឋាន ត្រូវចាត់តាំងជាការិយាល័យ ឬ ផ្នែក លើមុខជំនាញ ៣ គឺ "រដ្ឋបាល សរុបត្រួតពិនិត្យ និងទទួលពិនិត្យដោះស្រាយពាក្យបណ្ដឹង" តាមការកំណត់រួមរបស់បក្ស និង រដ្ឋ ។

ដោយឡែកចំពោះទីស្ដីការរដ្ឋមន្ត្រី និង ស្ថាប័នថ្នាក់ប្រហាក់ប្រហែលនាយដ្ឋាន ដែលមិនទាន់ចាំបាច់ត្រូវចាត់តាំងគណៈកម្មាធិការត្រួតពិនិត្យ ក៏ត្រូវចាត់តាំងអោយមានកម្មាភិបាលមួយចំនួន ដើម្បីជួយដល់ប្រធានក្នុងការពិនិត្យដោះស្រាយបណ្ដឹងតវ៉ា និង បណ្ដឹងចរិយា ដែលស្ថិតក្នុងសមត្ថកិច្ចដោះស្រាយស្ថាប័នខ្លួន ដូចមានចែងក្នុងសារាចរណែនាំលេខ ០៣ ស.រ.ណ.ន

Downloaded from http://www.khmerlaws.com

ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៨៤ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី អំពីការអនុវត្តច្បាប់ស្តីពីការពិនិត្យដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងឧបហាររបស់ពលរដ្ឋ ។

*ខ — ចំពោះខេត្ត-ក្រុង :*

គ្រប់ខេត្តក្រុងទូទាំងប្រទេស ត្រូវចាត់តាំងគណៈកម្មាធិការត្រួតពិនិត្យថ្នាក់ស្មើមន្ទីរនានាជុំវិញខេត្ត-ក្រុង ។ គណៈកម្មាធិការត្រួតពិនិត្យខេត្ត-ក្រុង មានប្រធាន ០១ រូបជាសមាជិកគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង និងមានអនុប្រធានជំនួយការ ។ គណៈកម្មាធិការត្រួតពិនិត្យខេត្ត-ក្រុង ត្រូវចាត់តាំងជាការិយាល័យ ឬផ្នែកលើមុខជំនាញ ៣ គឺ "រដ្ឋបាលសរុបត្រួតពិនិត្យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និង ទទួលពិនិត្យដោះស្រាយពាក្យបណ្តឹង" តាមការកំណត់រូមរបស់បក្ស និង រដ្ឋ ។

*គ — ចំពោះស្រុក ទីរួមខេត្ត ខ័ណ្ឌ ស្រុកដាយក្រុង :*

ផ្អែកតាមសភាពការណ៍ និង ការរីកចំរើនខាងវិស័យការងារត្រួតពិនិត្យ ដំណើរការចាត់តាំងគណៈកម្មាធិការត្រួតពិនិត្យស្រុក ទីរួមខេត្ត ខ័ណ្ឌ ស្រុកដាយក្រុង ត្រូវអនុវត្តជាជំហាន ៗ និង ជ្រើសយកកន្លែងដែលចាំបាច់ និង មានលទ្ធភាព គោលគឺ ស្រុក ទីរួមខេត្ត ខ័ណ្ឌ ស្រុកដាយក្រុង ដែលគ្រប់លក្ខណសម្បត្តិដូចខាងក្រោម :

— មានគណៈកម្មាធិការបក្សបណ្តោះអាសន្ន ដឹកនាំ
— ជាមូលដ្ឋានរឹងមាំខាងនយោបាយ និង ចាត់តាំង
— ជាមូលដ្ឋានដែលមានប្រភព សេដ្ឋកិច្ចសំខាន់ ៗ ច្រើន

ចំពោះមុខ គឺចុងឆ្នាំ ១៩៨៧ និង ដើមឆ្នាំ ១៩៨៨ អនុញ្ញាតអោយបណ្តាខេត្ត-ក្រុង នៅតំបន់វាលរាប តំបន់ជាប់សមុទ្រ ជ្រើសរើសយកស្រុក ១ និង ទីរួមខេត្ត ១ ដែលមានគ្រប់លក្ខណសម្បត្តិខាងលើ ចាត់តាំងបង្កើតគណៈកម្មាធិការត្រួតពិនិត្យដើម្បីដកពិសោធន៍ ។ ចុងឆ្នាំ ១៩៨៨ ឆ្នាំបន្តបន្ទាប់ អាចជ្រើសរើសយកស្រុកមួយចំនួនដែលមានគ្រប់លក្ខណម្បត្តិ ដើម្បីចាត់តាំងគណៈកម្មាធិការត្រួតពិនិត្យ ។

គណៈកម្មាធិការត្រួតពិនិត្យស្រុក ទីរួមខេត្ត ខ័ណ្ឌស្រុកដាយក្រុង មានថ្នាក់ស្មើការិយាល័យនានាជុំវិញស្រុក ទីរួមខេត្ត ខ័ណ្ឌ ស្រុកដាយក្រុង ដែលមានសមាជិកគណៈកម្មាធិការ-ប្រជាជនបដិវត្ត ១ រូប ទទួលបន្ទុកការងារនេះ មានអនុប្រធាន ១ រូប ទទួលជំនាញ និង មានកម្មាភិបាលមួយចំនួនជំនួយការ ។

Downloaded from http://www.khmerlaws.com

*២ – ជ្រើសរើសតែងតាំង និង ផ្លាស់ប្តូរភារកិច្ច :*

ផ្អែកតាមលក្ខណៈសម្បត្តិ ៦ យ៉ាងរបស់កម្មាភិបាលបដិវត្ត ការជ្រើសរើសកម្មាភិបាលត្រួតពិនិត្យ ត្រូវយកចិត្តទុកដាក់ចំណុចមួយចំនួន ដូចតទៅ :

មានទស្សនៈគោលជំហររឹងមាំ ស្មោះត្រង់ យុត្តិធម៌ សត្យានុម័តក្នុងការវាយតម្លៃសន្និដ្ឋាន និង សំណូមពរ ។

— មានអត្តចរិត និង សីលធម៌បដិវត្តល្អប្រសើរ

— ចាំបាច់ត្រូវមានសមត្ថភាពយល់ដឹង ទាំងខាងនយោបាយ និង មុខជំនាញបច្ចេកទេសភ្ជាប់ជាប់មាគ៌ា គោលនយោបាយរបស់បក្ស ច្បាប់របស់រដ្ឋ និង មានគំនិតយល់ដឹងអំពីការគ្រប់គ្រងសេដ្ឋកិច្ច_សង្គមកិច្ច ។

មានវិធីសាស្ត្រធ្វើការងារបានត្រឹមត្រូវ ត្រូវចេះផ្អែកលើមហាជន ដើម្បីអនុវត្តការងារនិងជាជំហាន ៗ ត្រូវចេះប្រើប្រាស់នូវវិធីវិចារវិទ្យាសម្ភារៈនិយម ក្នុងការងាររបស់ខ្លួន ។

— ក្នុងការតែងតាំងតម្លើងឋានៈ និង ផ្លាស់ប្តូរភារកិច្ច សមមិត្តប្រធាន ឬ អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យ ត្រូវទទួលខុសត្រូវតាមលក្ខការណ៍ដូចខាងក្រោម :

— ចំពោះសមមិត្តប្រធាន ឬ អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យ របស់ទីស្តីការរដ្ឋមន្ត្រី និង ស្ថាប័នថ្នាក់ប្រហាក់ប្រហែលនោមជ្ឈិម គឺអាស្រ័យដោយសមមិត្តរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នពិនិត្យជ្រើសរើស រួចស្នើឡើងថ្នាក់លើពិនិត្យសំរេច ក្រោយបានការឯកភាពពីក្រសួងត្រួតពិនិត្យ ។

— ចំពោះសមមិត្តប្រធានគណៈកម្មាធិការត្រួតពិនិត្យ ខេត្ត-ក្រុង គឺអាស្រ័យដោយគណៈកម្មាធិការប្រជាជនបដិវត្ត ខេត្ត-ក្រុង ពិនិត្យជ្រើសរើស រួចស្នើឡើងថ្នាក់លើពិនិត្យសំរេច ក្រោយបានការឯកភាពពីក្រសួងត្រួតពិនិត្យ ។ ដោយឡែកសមមិត្តអនុប្រធាន គឺអាស្រ័យដោយគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ពិនិត្យសំរេច ក្រោយបានការឯកភាពពីក្រសួងត្រួតពិនិត្យ ។

— នៅស្រុក ទីរួមខេត្ត ខណ្ឌ ស្រុកជាយក្រុង ត្រូវជ្រើសរើសយកសមមិត្ត ជាសមាជិកគណៈកម្មាធិការប្រជាជនបដិវត្តស្រុក ទីរួមខេត្ត ខណ្ឌ ស្រុកជាយក្រុងម្នាក់ អោយទទួលបន្ទុកការងារត្រួតពិនិត្យ ក្រោយពីបានការឯកភាពពីគណៈកម្មាធិការត្រួតពិនិត្យខេត្ត-ក្រុង របស់ខ្លួន ។ ឯសមមិត្ត អនុប្រធានដែលទទួលបន្ទុកការងារជំនាញត្រួតពិនិត្យ គឺអាស្រ័យដោយគណៈកម្មាធិការប្រជាជនបដិវត្តស្រុក ទីរួមខេត្ត ខណ្ឌ ស្រុកជាយក្រុង ពិនិត្យសំរេច ក្រោយពីបានការឯកភាពជាមួយគណៈកម្មាធិការត្រួតពិនិត្យ ខេត្ត - ក្រុង របស់ខ្លួន ។

Downloaded from http://www.khmerlaws.com

— ក្នុងករណីចាំបាច់ត្រូវផ្លាស់ប្តូរប្រធាន ឬ អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ទៅអង្គភាពផ្សេងនោះ ត្រូវមានការឯកភាពពីស្ថាប័នត្រួតពិនិត្យថ្នាក់លើផ្ទាល់ ។

III- *របៀបរបបធ្វើការ និង ទំនាក់ទំនងការងារ :*

ដើម្បីធានាដល់ការចាត់តាំង និង ធ្វើសកម្មភាពរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ អោយប្រព្រឹត្តទៅបានល្អប្រសើរ សមស្របនឹងសមត្ថភាពដឹកនាំ និង ស៊ីសង្វាក់គ្នាពីលើដល់ក្រោម ក្រសួងត្រួតពិនិត្យសូមកំណត់នូវរបៀបរបបធ្វើការ និង ទំនាក់ទំនងការងារ ដូចតទៅ ៖

*១ — របៀបរបបធ្វើការងារ*

គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ត្រូវធ្វើការងារតាមរបបប្រធានដឹកនាំ បុគ្គលទទួលខុសត្រូវ ដោយរួមផ្សំយ៉ាងជិតស្និទ្ធ និង ពិគ្រោះពិភាក្សាជាសមូហភាព ចំពោះបណ្តាបញ្ហាណា ដែលមានសារៈសំខាន់ ។

ប្រធានគណៈកម្មាធិការត្រួតពិនិត្យ ត្រូវទទួលខុសត្រូវចំពោះថ្នាក់ដឹកនាំផ្ទាល់ លើការងារត្រួតពិនិត្យទាំងមូល និង ទទួលខុសត្រូវក្នុងការណែនាំមុខជំនាញត្រួតពិនិត្យចំពោះកម្មាភិបាលថ្នាក់ខ្លួន ។ គណៈកម្មាធិការត្រួតពិនិត្យថ្នាក់ក្រោម និង គណៈកម្មាធិការត្រួតពិនិត្យរបស់ប្រជាជននៅមូលដ្ឋាន ។ អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ទទួលដឹកនាំរួមពេលប្រធានអវត្តមាន " អាស្រ័យដោយប្រធានប្រគល់សិទ្ធិ " និង ទទួលបន្ទុកការងារជំនាញមួយចំនួនតាមការប្រគល់សិទ្ធិពីប្រធាន ។ ដោយឡែក អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យស្រុក ទីរួមខេត្ត ខណ្ឌ ស្រុកជាយក្រុង ត្រូវទទួលខុសត្រូវខាងមុខជំនាញត្រួតពិនិត្យ ចំពោះគណៈកម្មាធិការប្រជាជនបដិវត្តស្រុក ទីរួមខេត្ត ខណ្ឌ ស្រុកជាយក្រុង ។ នៅពេលអវត្តមាន ត្រូវប្រគល់សិទ្ធិជូនកម្មាភិបាលដែលមានសមត្ថភាព និង លទ្ធភាព ទទួលការងារជំនួស ។

ប្រធាន ឬ អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ត្រូវបានអញ្ជើញអោយចូលរួមរាល់ការប្រជុំរបស់ថ្នាក់ដឹកនាំស្ថាប័នថ្នាក់លើដែលគ្រប់គ្រងផ្ទាល់ ក្នុងពេលមានទំនាក់ទំនងការងារត្រួតពិនិត្យដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន ។

ជាមួយនេះដែល គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ត្រូវតែកំណត់របបប្រជុំផ្សេង ៗ អោយបានសមស្របតាមរបៀបរបបធ្វើការខាងលើនេះ និង តាមស្ថានភាពការណ៍ជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ។ម្យ៉ាងទៀត ត្រូវអនុវត្តរបបរាយការណ៍អោយបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស ៩ ខែ និង ប្រចាំឆ្នាំ ជូនស្ថាប័នត្រួតពិនិត្យថ្នាក់លើ និង ជូនថ្នាក់ដឹកនាំរបស់ខ្លួន ។

Downloaded from http://www.khmerlaws.com

*២ — ទំនាក់ទំនងរវាងស្ថាប័នត្រួតពិនិត្យគ្រប់ថ្នាក់ ជាមួយស្ថាប័នបក្ស រដ្ឋអំណាច និង អង្គការមហាជន*

*ក — ទំនាក់ទំនងជាមួយស្ថាប័នត្រួតពិនិត្យថ្នាក់លើរបស់ខ្លួន*

ផ្អែកតាមក្រឹត្យ-ច្បាប់ លេខ ៣១ ក្រ.ច ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋ ក្រសួងត្រួតពិនិត្យមានភារកិច្ចណែនាំរាល់ការងារត្រួតពិនិត្យរបស់រដ្ឋ និង ការងារត្រួតពិនិត្យរបស់ប្រជាជន ដោយត្រូវផ្សព្វផ្សាយបំពាក់បំប៉នដល់គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ខាងមុខជំនាញបច្ចេកទេស និង ខ្លឹមសារការងារត្រួតពិនិត្យ ។ ទន្ទឹមនឹងនេះ ក្រសួងត្រួតពិនិត្យនៅមានភារកិច្ចតាមដាន ណែនាំ និង ត្រួតពិនិត្យជាប្រចាំ ទាន់ពេលវេលា នូវរាល់កិច្ចការរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ទាំងកិច្ចការដែលធ្វើបានល្អ ឬ មិនបានល្អ ទាំងការលំបាក ឬ ការរាំងស្ទះ ដើម្បីជួយកែលំអ និង សម្រួល ក្នុងគោលបំណងជួយជំរុញការងាររបស់ក្រសួង ខេត្ត-ក្រុង អោយប្រព្រឹត្តទៅបានល្អ ។

ដើម្បីធានារឹងមាំក្នុងទំនាក់ទំនងនេះ គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ត្រូវចេះទទួលយកការណែនាំមុខជំនាញ ទៅប្រើប្រាស់ក្នុងការចាត់តាំង និង សកម្មភាពត្រួតពិនិត្យនៅមូលដ្ឋានរបស់ខ្លួនអោយបានល្អប្រសើរ ដោយចេះគួបផ្សំនូវរាល់សំណូមពរ ទិសដៅ និង ផែនការណែនាំរបស់ស្ថាប័នត្រួតពិនិត្យថ្នាក់លើ ដើម្បីបង្កើនប្រសិទ្ធភាពការងារ និង ធានាបានរាល់ភារកិច្ចដឹកនាំនៃស្ថាប័នដឹកនាំរបស់ខ្លួន ។ ម្យ៉ាងទៀត នៅពេលក្រសួងត្រួតពិនិត្យ ឬ គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ចុះទៅធ្វើសកម្មភាពនៅមូលដ្ឋានរបស់ខ្លួន ចាំបាច់ត្រូវចូលរួមសហការយ៉ាងសកម្ម និងត្រូវបង្កលក្ខណៈងាយស្រួលដល់ការងារត្រួតពិនិត្យ ដូចជាផ្តល់សភាពការណ៍ ចាត់តាំងកម្មាភិបាលចូលរួមប្រាស្រ័យការងារជាដើម ។

*ខ — ទំនាក់ទំនងជាមួយស្ថាប័នតុលាការ អយ្យការ នគរបាល និងអង្គការបក្ស*

គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ចាំបាច់ត្រូវយកចិត្តទុកដាក់ផ្សារភ្ជាប់ចំណងទាក់ទងសហការយ៉ាងជិតស្និទ្ធ និង ទទួលការឧបត្ថម្ភពីសំណាក់ស្ថាប័នទាំងឡាយដូចពោលខាងលើ ដើម្បីចូលរួមពិភាក្សាប្តូរយោបល់ សន្និដ្ឋាន និង ដោះស្រាយបញ្ហាដែលមានសារៈសំខាន់ និងមានទំនាក់ទំនងរួម ដោយផ្អែកលើមូលដ្ឋាននៃតួនាទី ភារកិច្ច ដោយឡែករៀងៗ ខ្លួន ។

*គ — ទំនាក់ទំនងជាមួយស្ថាប័នគ្រប់គ្រងនានា ពិសេសផ្នែកគ្រប់គ្រងសេដ្ឋកិច្ច ផែនការ និង ហិរញ្ញវត្ថុ*

Downloaded from http://www.khmerlaws.com

គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ត្រូវផ្ទៀតយកការជួយឧបត្ថម្ភសហការពីផ្នែកទាំងនេះ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការក្តាប់គោលការណ៍ ទិសដៅភារកិច្ច ការងាររបស់បក្ស រដ្ឋាភិបាល អោយបានទាន់ពេលវេលានៃការអភិវឌ្ឍន៍ឡើងតាមកាលៈទេសៈនីមួយ ៗ និង ដើម្បីចូលរួមចូលយោបល់ពិគ្រោះពិភាក្សាដោះស្រាយអោយបានល្អ រាល់បញ្ហាដែលមានការទាក់ទងដល់ការងារត្រួតពិនិត្យ

*ឃ – ទំនាក់ទំនងជាមួយអង្គការមហាជន ស្ថាប័នពត៌មាន កាសែត វិទ្យុ*

ត្រូវសហការជាមួយអង្គការមហាជន ស្ថាប័នពត៌មាន កាសែត វិទ្យុ ដើម្បីចាត់តាំងបំផុសលើកទឹកចិត្តជនគ្រប់រូប អោយចូលរួមធ្វើសកម្មភាពត្រួតពិនិត្យ និង រួមពិនិត្យតាមដានការងាររបស់ស្ថាប័នរដ្ឋទាំងឡាយ ។

ក្នុងនោះ ត្រូវមានផែនការឃោសនាពន្យល់អោយបានទូលំទូលាយ ស៊ីជំរៅចូលក្នុងប្រជាជនអំពីគោលបំណង អត្ថន័យនៃការងារត្រួតពិនិត្យ ឧទ្ទេសនាមនូវសកម្មភាពមួយចំនួននៃការងារត្រួតពិនិត្យ និងការងារពិនិត្យដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងបរិហាររបស់ពលរដ្ឋ ប្រសិនបើឃើញថាចាំបាច់ ។

នេះជាការណែនាំរួមនូវចំណុចសំខាន់ ៗ នៃតួនាទីភារកិច្ច សិទ្ធិអំណាច អង្គការចាត់តាំង របៀបរបបធ្វើការងារ និង ទំនាក់ទំនងការងាររបស់គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ឯការកំណត់នូវតួនាទី ភារកិច្ច សិទ្ធិអំណាច អង្គការចាត់តាំង របៀបរបបធ្វើការ និង ទំនាក់ទំនងការងាររបស់គណៈកម្មាធិការត្រួតពិនិត្យនៃថ្នាក់នីមួយ ៗ ជាក់ស្តែងនោះគឺអាស្រ័យដោយ សមមិត្ត រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង គណៈកម្មាធិការប្រជាជនបដិវត្តគ្រប់ថ្នាក់ ផ្អែកលើសារាចរណែនាំនេះ និង សំណូមពរការងារ ដើម្បីកំណត់ដាក់ចេញអោយអនុវត្ត ។

រាល់សេចក្តីកំណត់ទាំងឡាយពីមុនដែលផ្ទុយពីសេចក្តីកំណត់ក្នុងសារាចរណែនាំនេះ ត្រូវទុកជានិរាករណ៍ ។

ន័យ និង ខ្លឹមសារក្នុងសារាចរណែនាំដូចបានជំរាបជូនខាងលើ សូមសមមិត្តរដ្ឋមន្ត្រី សមមិត្តថ្នាក់ដឹកនាំស្ថាប័ន ថ្នាក់ប្រហាក់ប្រហែលនៅមជ្ឈិម សមមិត្តប្រធានគណៈកម្មាធិការប្រជាជនបដិវត្តគ្រប់ថ្នាក់ ជ្រាប និង លើកកំពស់ស្មារតីអនុវត្តអោយបានល្អប្រសើរ និង ប្រកបដោយជោគជ័យ ។

គោរពជូនពរ សុខភាពល្អ និង ជ័យជំនះ

*ភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៨៨*

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

Downloaded from http://www.khmerlaws.com

សហគ្រាសសម្ព័ន្ធរោងពុម្ពទី ២

បោះពុម្ពនៅរោងពុម្ពសុខាភិបាល

លើកទី ១ ចំនួន ៩.០០០ ច្បាប់

Downloaded from http://www.khmerlaws.com